អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**
Victims Support Section
Section d’appui aux victimes

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## អង្គភាពគាំពារជនរងគ្រោះរៀបចំវេទិកាថ្នាក់តំបន់លើកទី៣សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៃសំណុំរឿង ០០២ នៅទីរួមខេត្តស្វាយរៀង

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំ វេទិកាថ្នាក់តំបន់លើកទី៣សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២ ចំនួន **៣៥០** នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះមកពីតំបន់ភាគខាងកើតនៃប្រទេសកម្ពុជា រួមមាន ខេត្តព្រៃវែង កណ្តាល កំពង់ចាម និងស្វាយរៀង។ វេទិកាថ្នាក់តំបន់នេះនឹងប្រព្រឹត្តិទៅនៅ**ថ្ងៃព្រហស្បតិ៍ ទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ នៅសាលប្រជុំផ្ទេរទន្លេ ទីរួមខេត្តស្វាយរៀងចាប់ពីម៉ោង៧:៣០ព្រឹក** *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានរក្សាការសំងាត់)* ។

វេទិកាថ្នាក់តំបន់នេះគឺជាមធ្យោបាយមួយយ៉ាងសំខាន់ក្នុងចំណោមសកម្មភាពនានារបស់អង្គភាពគាំពារជនរងគ្រោះក្នុងការអនុវត្តគំរោងនៃការចូលរួមរបស់ជនរងគ្រោះឲ្យកាន់តែធំធេងក្នុងដំណើរការរបស់អ.វ.ត.ក ក្នុងឆ្នាំ២០១១ ដើម្បីពង្រឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវតុលាការសម្រាប់សំណុំរឿង ០០២នេះ។ វេទិកាថ្នាក់តំបន់នេះមានគោលបំណងលើកកម្ពស់ដល់ការចូលរួមរបស់ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី នៅទីកន្លែងមានសុវត្ថិភាពនិងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណី ៖

- ជួបជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សាអំពីសិទ្ធិក្នុងដំណើការជម្រះក្តីនិងជាពិសេសប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងជារួមដើម្បីរៀបចំគម្រោងទាមទារសំណង។
- ជួបជាមួយមន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវឌ្ឍន៍ថ្មីៗរបស់ អ.វ.ត.ក ។
- ជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២។

វេទិកាថ្នាក់តំបន់បែបនេះគឺរៀបចំបានជោគជ័យច្រើនដងរួចមកហើយលើកទី១ បានប្រព្រឹត្តិទៅនៅខេត្តក្រចេះ និងបន្ទាប់មកលើកទី២នៅខេត្តកំពត ដោយមានអ្នកចូលរួមដែលជាដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន៧០០នាក់ មកពី ១១ ខេត្ត ។ អង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក នឹងរៀប

ចំវេទិកាថ្នាក់តំបន់ចំនួនបីលើកទៀតនៅ តំបន់ដទៃទៀតអោយបានមុនសវនាការសំណុំរឿង០០២ ដែលចាប់ផ្តើមក្នុងឆ្នាំ២០១១ ក្នុងបំណងធ្វើយ៉ាងណាឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ដែលមានដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាងពីរពាន់នាក់ បានជួបជាមួយតំណាងផ្លូវច្បាប់របស់ខ្លួន ក៏ដូចជា មន្ត្រីនានានៃអ.វ.ត.ក ។

---

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក អ៊ីម សុភា ប្រធានកម្មវិធីផ្សព្វផ្សាយ
ទូរស័ព្ទ លេខ ០៧៧ ៧៧៧ ៣៦៧, ០៩៧៧៤២៤២១៨
០២៣ ២១៩៨១៤ ភ្ជាប់មកលេខ៖៦៦០២
សារអេឡិកត្រូនិក im.sophea@eccc.gov.kh